ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ០៣៧/១៦ ៦៩ អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦

# របាយការណ៍
## ស្ដីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែឧសភា ឆ្នាំ២០១៦ និងទិសដៅការងារ ខែមិថុនា ឆ្នាំ២០១៦

(ពីថ្ងៃទី២៦/០៤/២០១៦ - ២៥/០៥/២០១៦)

យោងតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញកាលពីខែមេសា ឆ្នាំ២០១៦ កន្លងទៅ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងគោលដៅចូលរួមចំណែកអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពជូនប្រជាពលរដ្ឋ ។ តាមរយៈការអនុវត្តផែនការសកម្មភាពនៃទិសដៅការងារខាងលើ នៅក្នុងខែឧសភានេះ យើងបានធ្វើការកត់សម្គាល់ទៅលើសភាពការណ៍ និងអនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែឧសភាឆ្នាំ២០១៦នេះ មន្ទីរប្រឆាំងគ្រឿងញៀន, ស្នងការដ្ឋាននគរបាលចំនួន ២៣ រាជធានី-ខេត្ត និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ១៨ រាជធានី-ខេត្ត (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣) បានបើកកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនទទួលបានលទ្ធផលល្អប្រសើរ ។ ក្នុងចំណោមបទល្មើសគ្រឿងញៀន ដែលបង្ក្រាបបាននៅក្នុងខែឧសភានេះ មានបទល្មើសជួញដូរគ្រឿងញៀនចំនួន ៣ ករណីធំៗ (គិតចាប់ពីជាង ៩០០ ក្រាមឡើងទៅ) ដែលបង្ក្រាបដោយមន្ទីរប្រឆាំងគ្រឿងញៀន, ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ប្រចាំការនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សហការជាមួយមន្ទីរប្រឆាំងគ្រឿងញៀន ដោយបានចាប់យកមេតំហ្វេតាមីនក្រាមម្សៅ (ICE) និង កូកាអ៊ីន ស្មើនឹងជិត ៧០ % នៃចំនួនគ្រឿងញៀនសរុប ដែលបានចាប់យកនៅក្នុងខែឧសភា ព្រមទាំងឃាត់ខ្លួនជនសង្ស័យជាជនជាតិឡាវ ០២ នាក់ និងជនជាតិនីហ្សេរីយ៉ា ០៥ នាក់ ។

គួរកត់សម្គាល់ បទល្មើសនាំកូកាអ៊ីនឆ្លងដែនមួយករណី ត្រូវបានជនសង្ស័យជាជនជាតិនីហ្សេរីយ៉ា ០២ នាក់ ធ្វើសកម្មភាពនាំពីអាកាសយានដ្ឋាន MURTALA MOHAMAD AIRPORT ប្រទេសនីហ្សេរីយ៉ា ឆ្លងកាត់អាកាសយានដ្ឋានទីក្រុង DUBAI ប្រទេសអារ៉ាប់រួម, ទីក្រុងដូហា ប្រទេសកាតា និងទីក្រុងហូជីមិញ ប្រទេសវៀតណាម រួចទើបចូលមកកម្ពុជាតាមអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដោយប្រើល្បិចលេបទុកក្នុងពោះ ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

## II. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តដឹកនាំ និងណែនាំលើការងារជាគោលសំខាន់ៗសម្រាប់អនុវត្តនៅក្នុងខែឧសភានេះ ក៏ដូចជាបណ្តាខែខាងមុខមានដូចតទៅ ៖

**១. ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ត្រូវត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៦ ។ ជាមួយនេះ ត្រូវបន្តការអប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមសហគមន៍ ព្រមទាំងយកចិត្តទុកដាក់ លើការអប់រំដល់បុគ្គលិក កម្មករនៅតាមរោងចក្រ សហគ្រាស និងពលករ ដែលត្រៀមទៅធ្វើការនៅក្រៅប្រទេស និងការងារបណ្តុះបណ្តាលក្រុមជនបង្គោល ។

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ៖** ក្រសួងសុខាភិបាលត្រូវបន្តរៀបចំបង្កើតមណ្ឌលសុខភាពនៅក្នុងមណ្ឌលឱកាសខ្ញុំ ។ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រូវពិភាក្សាជាមួយក្រសួង-ស្ថាប័ននានា ពាក់ព័ន្ធនឹងការព្យាបាលពិរុទ្ធជន-ទណ្ឌិត ដែលញៀនគ្រឿងញៀននៅតាមមន្ទីរអប់រំកែប្រែនិងពន្ធនាគារ និងពង្រឹងគុណភាព សមត្ថភាពនៃការព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមណ្ឌលបណ្តោះអាសន្ន និងនៅតាមសហគមន៍ ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖** ត្រូវបន្តបើកវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) និងតាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (E-Learning) និងពង្រឹងយន្តការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** ត្រូវរៀបចំផែនការ និងយន្តការដាក់លាក់សម្រាប់គ្រប់គ្រង ត្រួតពិនិត្យតាមដានលើការនាំចូល និងការប្រើប្រាស់សារធាតុគីមីផ្សំ និងបន្តប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** ត្រូវបន្តកិច្ចសហប្រតិបត្តិការជាមួយភាគីថៃ ឡាវ និងវៀតណាម ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន និងបន្តអនុវត្តនូវរាល់កិច្ចការដែលបានព្រមព្រៀងគ្នាកន្លងមក ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖** ត្រូវបន្តអនុវត្តនូវរាល់ខ្លឹមសារនៃកិច្ចព្រមព្រៀងនានា ទាំងក្នុងក្របខ័ណ្ឌ ទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ ជាពិសេស គម្រោងសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Project), គម្រោងពង្រឹងប្រសិទ្ធភាពការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងត្រូវធ្វើការបូកសរុប ដកពិសោធន៍ ពីលទ្ធផលដែលបានចុះជួយពង្រឹងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ក្នុងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

តាមប្រសាសន៍ណែនាំរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ និងទិសដៅដែលបានដាក់ចេញកាលពីខែមេសា អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តអនុវត្តការងារទទួលលទ្ធផលដូចខាងក្រោម ៖

## ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**-ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ ៖** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានរៀបចំ និងអញ្ជើញនាយកវិទ្យាល័យឥន្ទ្រទេវី និង វិទ្យាល័យព្រះស៊ីសុវត្ថិ ដើម្បីចូលរួមផ្តល់កិច្ចសម្ភាសន៍កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ នៅស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី តាមកម្មវិធី និងប្រធានបទ ដូចខាងក្រោម ៖

- កម្មវិធីព័ត៌មានពេលថ្ងៃ ស្តីពីសកម្មភាពអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅក្នុងវិទ្យាល័យឥន្ទ្រទេវី
- កម្មវិធីព័ត៌មានពេលល្ងាច ស្តីពីសកម្មភាពអប់រំ ផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀននៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ ។

**-ការងារអប់រំតាមសហគមន៍ ៖** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ, ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ៣ បានចុះអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមមូលដ្ឋានរបស់ខ្លួន (ឈ្មោះក្រសួង-ស្ថាប័ន-ខេត្ត និងវេទិកានានាដែលបានធ្វើសកម្មភាពបញ្ជ្រាបខ្លឹមសារអប់រំមាននៅក្នុងតារាងឧបសម្ព័ន្ធទី១) ។ លទ្ធផលជារួមមានមហាជនចូលរួមប្រមាណ **៦៤.៩៩២** នាក់ ។ ក្នុងនោះសកម្មភាពការងារអប់រំ ដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមអនុវត្តមានដូចខាងក្រោម ៖

១. បានចុះទៅផ្សព្វផ្សាយពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀននិងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ៖

- នៅតំបន់ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦
- នៅតំបន់ក្នុងសង្កាត់បឹងត្របែក ខណ្ឌចំការមន កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ។

ជាមួយនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយ ៖

- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះធ្វើការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ មាន មហាជនចូលរួមប្រមាណ ៣៦៧ នាក់
- ក្រសួងការពារជាតិ ធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅវិទ្យាស្ថានសុខាភិបាល ក្រសួងការពារជាតិ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០១៦ មានសិក្ខាកាមចូលរួមប្រមាណ ២៨០ នាក់ និងផ្សព្វផ្សាយដល់នាយ-នាយរង កងរាជអាវុធហត្ថ ២៥ រាជ ធានី-ខេត្ត កាលពី ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ មានមន្រ្តីចូលរួមប្រមាណ ២៨០ នាក់
- ក្រសួងទេសចរណ៍ផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងវគ្គបណ្តុះបណ្តាលស្តីពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងវិស័យទេសចរណ៍ និងយេនឌ័រ : នៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែឧសភា (អ្នកចូលរួមប្រមាណ ៥០ នាក់), ខេត្តកំពត ថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ២០១៦ (អ្នកចូលរួម ប្រមាណ ១៥០ នាក់)
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅរោងចក្រក្នុងរាជធានីភ្នំពេញ ១ កន្លែង (ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ អ្នកចូលរួមប្រមាណ ១៥០ នាក់) និងនៅរោងចក្រក្នុងខេត្តកណ្តាល ០១ កន្លែង (ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៦ អ្នកចូលរួម ៤៣០ នាក់) ។

២. បានផ្តល់កិច្ចសម្ភាសន៍នៅក្នុងកម្មវិធីជជែក ពិភាក្សាតាមទូរស័ព្ទ នៅវិទ្យុ អេហ្វ.អឹម ១០២ របស់

មណ្ឌលព័ត៌មានស្ត្រីកម្ពុជា ក្រោមប្រធានបទស្តីពីឥទ្ធិពលនៃគ្រឿងញៀន និងគ្រឿងស្រវឹងចំពោះកុមារ កាលពីថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៦ ។

៣. តាមរយៈការចលនាឱ្យមានការចូលរួមពីវិស័យឯកជន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត បានផ្តល់ជាខិត្តប័ណ្ណ ចំនួន ៥០.០០០ សន្លឹក សម្រាប់ប្រើប្រាស់លើការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

៤. បានសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍រដ្ឋ-ឯកជន, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកំពង់ស្ពឺ ស្វាយរៀង កណ្តាល និងខេត្តកំពង់ចាម និងវិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន តាមរយៈកម្មវិធីកម្សាន្តនានា និងកម្មវិធីផ្សព្វផ្សាយពាណិជ្ជកម្ម ដែលកម្មវិធីទាំងអស់នោះ មាននៅក្នុងតារាងឧបសម្ព័ន្ធទី១ ។

៥. បាន និងកំពុងបន្តដំណើរការផលិតផ្ទាំងប៉ាណូអប់រំពីបញ្ហាគ្រឿងញៀន សម្រាប់ដាក់នៅតាមតំបន់ព្រំដែន កម្ពុជា-ឡាវ ។

៦. តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែឧសភា ឆ្នាំ២០១៦ មានការចូលអានប្រមាណ **៥២.១៣០** ដង ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់ ៖

២.១.១. បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយជាផ្លូវការ ការអង្កេតជាតិស្តីពីការចំណាយក្នុងការប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់ឆ្នាំ២០១៣-២០១៥ កាលពីថ្ងៃទី០៥ខែឧសភាឆ្នាំ២០១៦ (មន្ត្រីអគ្គលេខាធិការដ្ឋាន០១រូប) ។

២.១.២. បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ សម្រាប់ប្រទេសកម្ពុជាទៅចូលរួមក្នុងកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់ជំងឺអេដស៍ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប) ។

### ២.២. ការព្យាបាល និងស្តារនីតិសម្បទា

២.២.១. បានចូលរួមប្រជុំជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តបន្ទាយមានជ័យ និងធ្វើទស្សនកិច្ចសិក្សាស្វែងយល់ពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅមណ្ឌលជីវិតថ្មីភ្នំបាក់ តាមការចង្អុលណែនាំរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ និងដឹកនាំដោយឯកឧត្តម អគ្គលេខាធិការ ពីថ្ងៃទី១៦-១៧ ខែឧសភា ឆ្នាំ២០១៦ (មន្ត្រីសរុប ៥៧ រូប, មន្ត្រីអគ្គលេខាធិការដ្ឋាន ០៣ រូប) ។

២.២.២. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញប្រកាសលេខ ១០០៤ ស.អ.យ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកំណត់របៀបរបបការងារ រវាងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ជាមួយអគ្គនាយកដ្ឋានបច្ចេកទេស ។

២.២.៣. បានចូលរួមប្រជុំក្រុមលេខាធិការ នៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ (មន្ត្រីសរុប ២៥ រូប, មន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប) ។

២.២.៤. បានដាក់បញ្ចូលគម្រោងផែនការសុំផ្តល់ជំនួយកសាងមជ្ឈមណ្ឌលជាតិស្តារនីតិសម្បទា និង

បណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នកជាសះស្បើយពីអាការៈញៀន ទៅក្នុងផែនការគម្រោងស្នើសុំជំនួយទ្វេភាគីពីរដ្ឋាភិបាលវៀតណាម (តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ) ។

២.២.៥. បាននិងកំពុងបន្តរៀបចំរបាយការណ៍វាយតម្លៃពីឱសថ បុងសែន ដែលបានប្រើប្រាស់ក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀន (រៀបចំដោយក្រសួងសុខាភិបាល) ។

២.២.៦. បានចូលរួមវគ្គបណ្តុះបណ្តាលសាកល្បងលើការព្យាបាល និងថែទាំអ្នកញៀនគ្រឿងញៀនតាមសហគមន៍នៅតំបន់អាស៊ីអាគ្នេយ៍ កាលពីថ្ងៃទី១០-១២ ខែឧសភា ឆ្នាំ២០១៦ នៅប្រទេសចិន (មន្ត្រីសរុប០២ រូប, មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប) ។

២.២.៧. បានចាត់បញ្ជូនមន្ត្រីចំនួន ០៣ រូប (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប, ក្រសួងសុខាភិបាល ០២ រូប) ទៅចូលរួមវគ្គបណ្តុះបណ្តាលអន្តរជាតិស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀន ពីថ្ងៃទី២៣ ខែឧសភា ដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ នៅប្រទេសថៃ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៣.១.១. បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ១២ រូប ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) វគ្គទី៣/ឆ្នាំ២០១៦ ពីថ្ងៃទី០២-០៦ ខែឧសភា ឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

៣.១.២. បានចូលរួមកិច្ចប្រជុំ ពិភាក្សាស្តីពីការពង្រឹងសមត្ថភាពមន្ត្រីតុលាការ និងនគរបាលយុត្តិធម៌ក្នុងការអនុវត្តច្បាប់ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌ កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ។

៣.១.៣. បានជួបពិភាក្សាការងារស្តីពីការវាយតម្លៃការជួញដូរគ្រឿងញៀនតាមកុងតឺន័រ (ចូលរួមដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ) កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ នៅទីស្នាក់ការកណ្តាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប) ។

៣.១.៤. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសហការជាមួយមជ្ឈមណ្ឌលព័ត៌មាននិងសហប្រតិបត្តិការសម្រាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន (APICC) របស់សាធារណរដ្ឋកូរ៉េ ៖

- រៀបចំនិងចូលរួមក្នុងសិក្ខាសាលាស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ (មន្ត្រីសរុប ៣៦ រូប, មន្ត្រីអគ្គលេខាធិការដ្ឋាន ០៥ រូប)
- រៀបចំពិធីទទួលសម្ភារចំនួន ១០ មុខ ពីមជ្ឈមណ្ឌលនេះ នៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១៦ ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣ ។

៣.១.៥. បានចាត់តាំងតំណាងរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ០១ រូប ដើម្បីធ្វើជាមន្ត្រីទំនាក់ទំនង (Focal point) ចូលរួមក្នុងការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាមួយក្រសួងយុត្តិធម៌ ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀន សរុប **២៧៤** ករណី លើ ៣២៩ ករណី នៃខែមេសា ឆ្នាំ២០១៦

- ជនសង្ស័យ ឃាត់ខ្លួន សរុប **៦៤៧** នាក់ (ស្រី ៦៩ នាក់) លើ ៧៦៩ នាក់ នៃខែមេសា ឆ្នាំ២០១៦

- ក្នុងបទល្មើសគ្រឿងញៀនទាំង ២៧៤ ករណី និងជនសង្ស័យទាំង ៦៤៧ នាក់ ខាងលើគឺ ៖

• បទល្មើសគ្រឿងញៀនបង្ក្រាបដោយ សមត្ថកិច្ចនគរបាល **២១១** ករណី, ជនសង្ស័យ **៤៥៨** នាក់

(ស្រី ៥២ នាក់)

- បទល្មើសគ្រឿងញៀនបង្ក្រាបដោយ **សមត្ថកិច្ចកងរាជអាវុធហត្ថ ៦៣** ករណី, ជនសង្ស័យ **១៩៩** នាក់ (ស្រី ១៧ នាក់)

- ក្នុងចំនួនជនសង្ស័យ ៦៤៧ នាក់ ខាងលើមាន ០៥ សញ្ជាតិគឺ ខ្មែរ ៦២៣ នាក់ (ស្រី ៦៤ នាក់), វៀតណាម ១៣ នាក់ (ស្រី ០៥ នាក់), កូរ៉េ ២ នាក់ (ប្រុស), ឡាវ ០៤ នាក់ (ប្រុស), នីហ្សេរីយ៉ា ០៥ នាក់ (ប្រុស) ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត

- **វត្ថុតាងគ្រឿងញៀនចាប់យក** ៖ មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៤គ.ក្រ ៦៤៩ក្រាម ៩៥ មេតំហ្វេតាមីនគ្រាប់ WY ២៥៩ក្រាម៩៦, កូកាអ៊ីន ១គ.ក្រ ០៣៩ក្រាម១០, កេតាមីន ០ក្រាម ២៩, កញ្ឆាក្រៀម ៨០ក្រាម ៥៤ (**សរុបគ្រឿងញៀនទាំងអស់មានចំនួន ៦ គ.ក្រ ០២៩ ក្រាម ៨៤**)

- **ទ្រព្យសម្បត្តិសំខាន់ៗ** ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន រួមមាន ៖ រថយន្ត ៧ គ្រឿង ម៉ូតូ ១៣៤ គ្រឿង ប្រាក់កម្ពុជា ៥.៦២៧.០០០ រៀល ប្រាក់អាមេរិក ១១.៩១៤ ដុល្លារ , ប្រាក់វៀតណាម ១.៩០០.០០០ ដុង (ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៣)

- ជនសង្ស័យចាប់តាមដីកា មាន ១៦ ដីកា = ជនសង្ស័យ ១៦ នាក់ (ស្រី ០៣ នាក់) ក្នុងនោះ ជនជាតិកូរ៉េ ០១ នាក់ (ប្រុស), វៀតណាម ០១ នាក់ (ស្រី) ។

### ៣.៣. លទ្ធផលកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

សំណាកសង្ស័យជាគ្រឿងញៀនដែលបានធ្វើកោសល្យវិច័យក្នុង ខែឧសភា ឆ្នាំ២០១៦ សរុប ១១០ ករណី = ១២៩ សំណាក ក្នុងនោះ ៖

- **សំណាក វិជ្ជមានសារធាតុញៀន** មាន ១០៥ ករណី = ១២៣ សំណាក (៩៥,៣៤ %)គឺ ៖
  - មេតំហ្វេតាមីន ICE ៩៣ សំណាក = ៧២,០៩ %
  - មេតំហ្វេតាមីន WY ៣០ សំណាក = ២៣,២៥ %
- **សំណាក អវិជ្ជមានសារធាតុញៀន** ០៥ ករណី = ០៦ សំណាក (៤,៦៥ %)

- បានផ្តល់ ស្រោមវេចខ្ចប់វត្ថុតាងចំនួន ២៥០ ស្រោម, ម៉ាគ្វីតេស្ត ៧០ តេស្ត និងតេស្តរកសារជាតុញៀនក្នុងទឹកនោម ៨៤០ តេស្ត ជូនដល់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ, ស្វាយរៀង, កណ្តាល, កំពង់ធំ និងខេត្តបាត់ដំបង ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

ក្នុងខែឧសភាឆ្នាំ២០១៦នេះ ទិន្នន័យសារជាតុគីមីផ្សំពាក់ព័ន្ធនឹងតារាងទី IV នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានអនុញ្ញាតឱ្យនាំចូលសរុបមាន **៩២៣.៩៥០** គ.ក្រ ២ ក្រាម ៤៦០ មិល្លីក្រាម ក្នុងនោះ ៖

- មានបទដ្ឋានបច្ចេកទេសឱ្យនាំចូលដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម ចំនួន ៨៧៧.៤០០ គ.ក្រ
- មានអាជ្ញាប័ណ្ណឱ្យនាំចូលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំនួន ៤៦.៥០០ គ.ក្រ
- មានអាជ្ញាប័ណ្ណឱ្យនាំចូលដោយក្រសួងសុខាភិបាល ក្នុងទម្រង់ជាវត្ថុធាតុដើម ៥០ គ.ក្រ ២ ក្រាម ៤៦០ មិល្លីក្រាម

ដោយឡែក សារជាតុញៀននៅក្នុងតារាងទី II, III នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលសម្រាប់យកទៅផលិតជាឱសថ មាននៅក្នុងតារាងឧបសម្ព័ន្ធទី៣ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

៥.១. បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងចុះហត្ថលេខាលើកំណត់ហេតុស្តីពីកិច្ចសហប្រតិបត្តិការ ឆ្នាំ២០១៦ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ជាមួយក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ កាលពីថ្ងៃទី២៧-២៩ ខែមេសា ឆ្នាំ ២០១៦ នៅប្រទេសឡាវ ។

៥.២. បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងចុះហត្ថលេខាលើឯកសារបំពេញបន្ថែម នៃផែនការសហប្រតិបត្តិការឆ្នាំ២០១៦ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ជាមួយក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម កាលពីថ្ងៃទី១១ ឧសភា ឆ្នាំ២០១៦ (ធ្វើនៅទីស្តីការក្រសួងមហាផ្ទៃ) ។

៥.៣. ប្រតិភូនៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង បានរៀបចំកិច្ចប្រជុំជាមួយប្រតិភូខេត្តឡុងអាន (វៀតណាម) កាលពីថ្ងៃទី២៩ខែមេសាឆ្នាំ២០១៦ ដើម្បីផ្លាស់ប្តូរសភាពការណ៍នៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន (ភាគីកម្ពុជា ៣៩ នាក់ / វៀតណាម ១៦ នាក់) ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

៦.១. បានចូលរួមកិច្ចប្រជុំពិសេសនៃមហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីបញ្ហាគ្រឿងញៀនពិភពលោក ពីថ្ងៃទី១៨-២០ ខែមេសា ឆ្នាំ២០១៦ នៅទីក្រុងញូវយ៉ក (ដោយស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំអង្គការសហប្រជាជាតិ) ។

៦.២. បានចូលរួមក្នុងសន្និសីទថ្នាក់តំបន់ លើកទី២ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងព្រំដែននៅអាស៊ាន ពីថ្ងៃទី២៥-២៦ ខែមេសា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប) ។

៦.៣. បានទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបញ្ហាការអង្គភាពគ្រឿងញៀនណាកូទិច នៅបណ្ឌិត្យសភាអនុវត្តន៍ច្បាប់អន្តរជាតិ នាទីក្រុងបាងកក ប្រទេសថៃ ពីថ្ងៃទី២៥ខែមេសា ដល់ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប) ។

៦.៤. បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការមន្ត្រីជាន់ខ្ពស់ នៃបណ្តាប្រទេសហត្ថលេខីលើអនុស្សរណៈនៃការយោគយល់គ្នា ឆ្នាំ១៩៩៣ កាលពីថ្ងៃទី២៣-២៥ ខែឧសភា ឆ្នាំ២០១៦ នៅប្រទេសថៃ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០២ រូប) ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៧.១. បានចូលរួមសន្និបាតបូកសរុបការងារយុត្តិធម៌ឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦ របស់ក្រសួងយុត្តិធម៌ កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ។

៧.២. បានចេញប្រកាសរួមចំនួនពីរ ពាក់ព័ន្ធនឹងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀនគឺ ៖

- ប្រកាសរួម លេខ ៥៧៦ សហវ.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន
- ប្រកាសរួម លេខ ៥៧៧ សហវ.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីការបង្ក្រាបបទល្មើសគ្រឿងញៀន (ដូចមានប្រកាសទាំងពីរជូនភ្ជាប់ជាមួយ) ។

៧.៣. បានបន្តចុះពង្រឹងការអនុវត្តបទបញ្ជាលេខ ០១ បប របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងវិធានការ

ប្រយុទ្ធប្រឆាំងគ្រឿងញៀន ដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ។

៧.៤. បានស្នើសុំគោលការណ៍ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ដើម្បីរៀបចំកិច្ចប្រជុំអន្តរក្រសួង ពិនិត្យលើផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧.៥. បាននិងកំពុងបន្តការរៀបចំសេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៦. បាននិងកំពុងបន្តការកែសម្រួល សេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែមិថុនា ឆ្នាំ២០១៦

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

១.១. ត្រៀមរៀបចំ ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៦ ។

១.២. ត្រៀមរៀបចំ និងអញ្ជើញនាយកវិទ្យាល័យ ជាស៊ីមសាមគ្គី និង វិទ្យាល័យ ហ៊ុនសែនជម្ពូវ័ន ផ្ដល់បទសម្ភាសន៍ នៅស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី នាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ក្នុងកម្មវិធី ៖

- ព័ត៌មានពេលថ្ងៃ ក្រោមប្រធានបទស្ដីពីសកម្មភាពអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន នៅក្នុងវិទ្យាល័យ ជាស៊ីមសាមគ្គី
- ព័ត៌មានពេលល្ងាច ក្រោមប្រធានបទស្ដីពីសកម្មភាពអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន នៅក្នុងវិទ្យាល័យ ហ៊ុនសែនជម្ពូវ័ន ។

១.៣. បន្តចុះធ្វើសកម្មភាពអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងរោងចក្រនៅខេត្តព្រះសីហនុ ។

១.៤. ត្រៀមធ្វើការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនដល់កម្មករ ជាង និងបុគ្គលិកក្រុមហ៊ុនញូវប្រូដាកសិន គ្រុប ភី អិល ស៊ី ។

១.៥. បន្តសកម្មភាពផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមរោងចក្រសហគ្រាស ដោយសហការជាមួយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

១.៦. បន្តរៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងគូរគំនូរប្រឆាំងគ្រឿងញៀន ។

១.៧. បន្តសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត និងបណ្ដាក្រុមហ៊ុនឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងកម្មវិធីកម្សាន្តសប្បាយ និងកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជននានា ។

១.៨. បន្តចុះធ្វើសកម្មភាពអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន នៅតាមសាលារៀន និងគោលដៅងាយកើតមានបទល្មើសគ្រឿងញៀន ។

១.៩. បន្តចលនាឱ្យមានការចូលរួមក្នុងការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ពីអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ។

១.១០. រៀបចំក្រុមការងារចងក្រងបទពិសោធន៍ និងឯកសារបង្ការការប្រើបំពានគ្រឿងញៀននៅតាមសាលារៀន ។

១.១១. បន្តសហការជាមួយក្រសួងទេសចរណ៍ក្នុងការ ៖

- បញ្ច្រាបបន្ថែមសារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់ដែលបណ្តាលពីគ្រឿងញៀននៅក្នុងយុទ្ធនាការប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ
- ចែកខិត្តប័ណ្ណអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀននៅតាមគោលដៅទេសចរណ៍ ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

២.១. បន្តជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្មថែមទៀត ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបានដឹង និងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព ដែលនៅជិត ។

២.២. បន្តការកែសម្រួលនិងពង្រឹងសមត្ថភាព គុណភាពនៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

២.៣. បន្តជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ដើម្បីពង្រឹងយន្តការក្នុងការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

៣.១. ត្រៀមរៀបចំ និងចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីបញ្ហាគ្រឿងញៀន នៅតំបន់ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ក្រោមការដឹកនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ។

៣.២. សហការជាមួយអង្គការ UNODC រៀបចំសិក្ខាសាលាស្តីពីការប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀនសម្រាប់មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន (BLO) ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២០-២១ ខែមិថុនា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ។

៣.៣. បន្តបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ១២ រូប ស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) វគ្គទី៤/២០១៦ ។

៣.៤. បន្តបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀននិងឧក្រិដ្ឋកម្មឆ្លងដែនតាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (E-Learning) ។

៣.៥. ត្រៀមធ្វើបទឧទ្ទេសនាមក្នុងវគ្គបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ការទប់ស្កាត់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ដល់មន្ត្រីយោធានៅទីបញ្ជាការដ្ឋានវិស្វកម្ម នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ និងវគ្គបំប៉ន និងបណ្តុះបណ្តាលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និការទប់ស្កាត់ការជួញដូរ ការប្រើប្រាស់គ្រឿងញៀនដល់មន្ត្រីយោធាដែលជាជនបង្គោលមកពីបណ្តាកងឯកភាពនៃកងយោធពលខេមរភូមិន្ទ នៅក្រសួងការពារជាតិ ។

៣.៦. ត្រៀមចូលរួមកិច្ចប្រជុំ ពិភាក្សាពាក់ព័ន្ធនឹងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ។

៣.៧. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន ដល់មន្ត្រីពន្ធនាគារខេត្តកំពង់ធំ និងខេត្តសៀមរាប ។

៣.៨. ត្រៀមទៅចូលរួមសិក្ខាសាលាអាស៊ាន ស្តីពីការរឹបអូសទ្រព្យពីករណីផលិត និងជួញដូរគ្រឿងញៀន

ដែលនឹងប្រព្រឹត្តទៅនាខែមិថុនា ឆ្នាំ២០១៦ ។

៣.៩. ត្រៀមរៀបចំកិច្ចប្រជុំត្រួតពិនិត្យយន្តការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅទូទាំងប្រទេស ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ**

៤.១. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំ ។

៤.២. ត្រៀមរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិស្តីពី ការបិទស្លាកសញ្ញា ការទុកដាក់ ការវេចខ្ចប់នូវសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម (ដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម) ។

៤.៣. បន្តប្រមូលព័ត៌មានពាក់ព័ន្ធនឹងសារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

៤.៤. រៀបចំកែសម្រួលសមាសភាពក្រុមការងារ និងក្រុមលេខា នៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ។

៤.៥. សហការជាមួយអង្គការ UNODC រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តធ្វើតេស្តគ្រឿងញៀន និងសារធាតុគីមីផ្សំ ពីថ្ងៃទី១៩-២០ ខែកក្កដា ឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន**

៥.១. បន្តអនុវត្តគម្រោងទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៥-២០១៦ ជាមួយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ។

៥.២. ត្រៀមទទួលមន្ត្រីព័ត៌មានវិទ្យា (Information of Technology. IT) របស់ការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដើម្បីពិភាក្សាក្នុងការរៀបចំបង្កើត Tele - Video Conference នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ។

៥.៣. ត្រៀមពិធីទទួលសម្ភារជំនួយរបស់ការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB)។

៥.៤. ត្រៀមចូលរួមកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-វៀតណាម លើកទី៣ ដែលនឹងប្រព្រឹត្តទៅនៅប្រទេសវៀតណាម ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា**

៦.១. ត្រៀមចូលរួមកិច្ចប្រជុំ លើកទី២ ស្តីពីផែនការការងារ ASOD (ASEAN Senior Officials on Drug Matters. ASOD) ដើម្បីសន្តិសុខសហគមន៍ប្រឆាំងគ្រឿងញៀនខុសច្បាប់សម្រាប់ឆ្នាំ២០១៦-២០២៥ ដែលនឹងប្រព្រឹត្តទៅនៅប្រទេសថៃ ។

៦.២. ត្រៀមពិធីចុះហត្ថលេខាលើគម្រោងត្រួតពិនិត្យកុងតឺន័រ របស់អង្គការ UNODC ។

៦.៣. ត្រៀមទទួលតេស្តរកសារធាតុញៀនក្នុងទឹកនោម ពីគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀនចិន (NNCC)។

៦.៤. ត្រៀមចាត់បញ្ជូនមន្ត្រីទៅចូលរួមទស្សនកិច្ចសិក្សា ស្តីពីកិច្ចសហប្រតិបត្តិការរវាងការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-ថៃ ពីថ្ងៃទី០៦-០៩ ខែមិថុនា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

៦.៥. សហការជាមួយអង្គការ UNODC រៀបចំកិច្ចប្រជុំស្តីពីការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀននៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ។

៦.៦. បន្តសហការជាមួយអង្គការ UNODC ចុះទៅពិនិត្យស្ថានភាពភូមិសាស្ត្រនៅច្រកថ្មដា ស្រុកវាលវែង (ខេត្តពោធិ៍សាត់), ច្រកទ្វារអន្តរជាតិអូរយ៉ាដាវ (ខេត្តរតនគិរី) និង ច្រកអានសេះ (ខេត្តព្រះវិហារ) ដើម្បីពិនិត្យលទ្ធភាពក្នុងការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

៧.១. បន្តការកែសម្រួលសេចក្ដីសម្រេចស្ដីពី ការបង្កើតគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ។

៧.២. ត្រៀមរៀបចំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យលើផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧.៣. បន្តរៀបចំសេចក្ដីព្រាងព្រះរាជក្រឹត្យ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៤. រៀបចំលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**អគ្គលេខាធិការ**

**នាយឧត្តមសេនីយ៍ មាស-វិរិទ្ធ**

**ចម្លងជូន**
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ

  " ដើម្បីជូនជ្រាប "
- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.ញ
- ក្រសួងផែនការ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្ដីការគណៈរដ្ឋមន្ត្រី

  " ដើម្បីមុខការ "
- ឯកសារ